# នៅចំពោះមុខអង្គបុរេជំនុំជម្រះ
# នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| **សំណុំរឿងលេខ** | ៖ | ០០៤/២/០៧-០៩-២០០៩-អវតក/កសចស (អបជ ៦០) |
| **ដាក់ទៅ** | ៖ | អង្គបុរេជំនុំជម្រះ |
| **ថ្ងៃដាក់** | ៖ | ថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២០ |
| **ភាគីអ្នកដាក់** | ៖ | អោ អាន |
| **ភាសាដើម** | ៖ | អង់គ្លេស |

**ឯកសារបកប្រែ**
**TRANSLATION/TRADUCTION**
ថ្ងៃ ខែ ឆ្នាំ (Date): 04-Mar-2020, 15:39
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

**ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ៖** **សម្ងាត់**

**ចំណាត់ថ្នាក់ឯកសារកំណត់ដោយ អបជ៖** សាធារណៈ/Public

**ប្រភេទនៃចំណាត់ថ្នាក់ឯកសារ៖**

**ការពិនិត្យឯកសារបណ្ដោះអាសន្នឡើងវិញ៖**

**ឈ្មោះមន្ត្រីដែលបានពិនិត្យ៖**

**ហត្ថលេខា៖**

---

## សំណើសុំការបញ្ជាក់ថា បានចាត់វិធានការរដ្ឋបាលដែលចាំបាច់ទាំងអស់ដើម្បីរក្សាសំណុំរឿង ០០៤/០២ ទុកក្នុងបណ្ណសារ

---

**អ្នកដាក់ឯកសារ៖**
**សហមេធាវី**
មុំ លុជ្ស
Richard ROGERS
Göran SLUITER

**អ្នកទទួលឯកសារ៖**
**អង្គបុរេជំនុំជម្រះ**
ចៅក្រម ប្រាក់ គឹមសាន
ចៅក្រម Olivier BEAUVALLET
ចៅក្រម ន័យ ថុល
ចៅក្រម Kang Jin BAIK
ចៅក្រម ហួត វុទ្ធី

**សហព្រះរាជអាជ្ញា**
ជា លាង
Brenda J. Hollis

**អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ក្នុងសំណុំរឿង០០៤/២**

## សេចក្តីផ្តើម

1. អោ អាន តាមរយៈសហមេធាវីរបស់ខ្លួន (*"មេធាវីការពារក្តី"*) សូមស្នើសុំដោយគោរពដល់អង្គបុរេជំនុំជម្រះ (*"អ.ប.ជ"*) មេត្តាបញ្ជាក់ថា បានចាត់វិធានការរដ្ឋបាលដែលចាំបាច់ទាំងអស់ដើម្បីរក្សាសំណុំរឿង ០០៤/០២ ទុកក្នុងបណ្ណសារ។ អនុលោមតាមវិធាន ៦៩(២)(ខ) នៃវិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (*"វិធានផ្ទៃក្នុង និង អ.វ.ត.ក"*) ឯកសារសំណុំរឿងដែលលើកលែងការចោទប្រកាន់ *"ត្រូវបានរក្សាទុកក្នុងបណ្ណសារ"*។ សំណុំរឿងរបស់ អោ អាន ត្រូវបានលើកលែងចោទប្រកាន់នៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨[1] ហើយការលើកលែងចោទប្រកាន់មិនត្រូវបានបដិសេធដោយសារ *សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍*នៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ ទេ[2]។ វិធាន ៦៩(២)(ខ) តម្រូវឲ្យអង្គបុរេជំនុំជម្រះធ្វើការបោះត្រាលើសំណុំរឿង និងរក្សាទុកក្នុងបណ្ណសារ។ មកទល់នឹងពេលនេះ អោ អាន មិនទាន់បានទទួលការបញ្ជាក់ណាមួយថាសំណុំរឿង ០០៤/០២ ត្រូវបានបោះត្រា និងរក្សាទុកក្នុងបណ្ណសារទៅតាមការតម្រូវរបស់វិធានផ្ទៃក្នុងនៅឡើយទេ។ លទ្ធផលនៃភាពមិនច្បាស់លាស់ជាការរំលោភបំពានលើសិទ្ធិរបស់ អោ អាន ក្នុងការទទួលបានការសម្រេចជាស្ថាពរនៅក្នុងរឿងក្តីនេះ គោលការណ៍សច្ចភាពផ្លូវច្បាប់ និង បន្តប៉ះពាល់ដល់សុខុមាលភាពរបស់គាត់។ ហេតុនេះ មេធាវីការពារក្តីស្នើសុំដោយគោរពដល់អង្គបុរេមេត្តាបញ្ជាក់ថា បានចាត់វិធានការរដ្ឋបាលដែលចាំបាច់ទាំងអស់ដើម្បីរក្សាសំណុំរឿង ០០៤/០២ ទុកក្នុងបណ្ណសារ។

2. មេធាវីការពារក្តីសូមដាក់សំណើនេះជាភាសាអង់គ្លេសជាមុនសិន ចំណែកសំណៅបកប្រែជាភាសាខ្មែរនឹងដាក់តាមក្រោយឲ្យបានឆាប់តាមដែលអាចធ្វើបាន។

## ប្រវត្តិនីតិវិធី

3. នៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ សហចៅក្រមស៊ើបអង្កេតបានចេញដីកាដំណោះស្រាយពីរដាច់ដោយឡែកពីគ្នា និងផ្ទុយគ្នា នៅក្នុងសំណុំរឿង ០០៤/០២[3]។

---

[1] សំណុំរឿងលេខ ០០៤/២/០៧-០៩-២០០៩-អវតក/កសចស *ដីកាសម្រេចលើកលែងចោទប្រកាន់ អោ អាន* (*"ដីកាសម្រេចលើកលែងចោទប្រកាន់"*) ឯកសារ **D359** ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨។

[2] សំណុំរឿងលេខ ០០៤/២/០៧-០៩-២០០៩-អវតក/កសចស (អបជ ៦០) *សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ* (*"សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍"*) ឯកសារ **D359/24 & D360/33** ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩។

[3] សំណុំរឿងលេខ ០០៤/២/០៧-០៩-២០០៩-អវតក/កសចស *ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ)* ឯកសារ

4. នៅថ្ងៃទី ១៧ ខែធ្នូ ឆ្នាំ២០១៨ សហព្រះរាជអាជ្ញាជាតិ (*"ស.ព.ជ"*) បានដាក់បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹង*ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ)*[4]។ នៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៨ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹង *ដីកាសម្រេចលើកលែងចោទប្រកាន់ អោ អាន* (*"ដីកាសម្រេចលើកលែងចោទប្រកាន់"*)[5]។ នៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៨ ដូចគ្នា មេធាវីការពារក្ដីបានដាក់បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹង *ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ)*[6]។

5. នៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ អង្គបុរេបានចេញ *សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ* (*"សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍"*)។ អង្គបុរេបានសម្រេចជាឯកច្ឆ័ន្ទថា ការចេញដីកាដំណោះស្រាយពីរផ្ទុយគ្នាជារឿងខុសច្បាប់ ហើយអង្គបុរេមិនអាចរកបានសំឡេងភាគច្រើនលើសលប់ដើម្បីសម្រេចទៅលើអង្គសេចក្ដីនៃសារណាបណ្ដឹងឧទ្ធរណ៍របស់ភាគីបានឡើយ[7]។

6. នៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៩ មេធាវីការពារក្ដីបានផ្ញើលិខិតមួយច្បាប់ទៅអង្គជំនុំជម្រះសាលាដំបូង ដោយស្នើសុំការបញ្ជាក់ថា អង្គជំនុំជម្រះមិនបានទទួលយកសំណុំរឿង ០០៤/២ មកពិនិត្យតាមផ្លូវច្បាប់ទេ ហើយជាជម្រើសម្យ៉ាងទៀត ស្នើសុំពន្យាពេលវេលា និងការណែនាំសម្រាប់ដាក់អញ្ញត្រកម្មអនុលោមតាមវិធាន ៨៩[8]។

---

**D360** ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨។ *ដីកាសម្រេចលើកលែងចោទប្រកាន់*។

[4] សំណុំរឿងលេខ ០០៤/២/០៧-០៩-២០០៩-អវតក/កសចស (អបជ ៦០) *បណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិទាក់ទងនឹងដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ក្នុងសំណុំរឿង ០០៤/២* ឯកសារ **D360/8/1** ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៨។

[5] សំណុំរឿងលេខ ០០៤/២/០៧-០៩-២០០៩-អវតក/កសចស (អបជ ៦០) *បណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាសម្រេចលើកលែងចោទប្រកាន់ អោ អាន (D359)* (*"បណ្ដឹងឧទ្ធរណ៍របស់ ស.ព.ជ"*) ឯកសារ **D359/3/1** ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៨។

[6] សំណុំរឿងលេខ ០០៤/២/០៧-០៩-២០០៩-អវតក/កសចស (អបជ ៦០) *បណ្ដឹងឧទ្ធរណ៍របស់ អោ អាន លើដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ក្នុងសំណុំរឿង ០០៤/២* (*"បណ្ដឹងឧទ្ធរណ៍របស់ អោ អាន ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ"*) ឯកសារ **D360/5/1** ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៨។

[7] *សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍* កថាខណ្ឌ ១២៤, ១៦៩។

[8] ក្រុមមេធាវីការពារក្ដី អោ អាន *"សំណើសុំការបញ្ជាក់ថា អង្គជំនុំជម្រះមិនអាចទទួលយកសំណុំរឿង ០០៤/២ មកពិនិត្យតាមផ្លូវច្បាប់បាន ជាជម្រើសម្យ៉ាងទៀត សំណើសុំការពន្យារពេល និងការណែនាំសម្រាប់ការដាក់អញ្ញត្រកម្ម អនុលោមតាមវិធាន ៨៩ នៃវិធានផ្ទៃក្នុង"* ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៩ ត្រូវបានភ្ជាប់ជាឧបសម្ព័ន្ធ ១។

7. នៅថ្ងៃទី២១ ខែមករា ឆ្នាំ២០២០ ក្រឡាបញ្ជីនៃអង្គជំនុំជម្រះសាលាដំបូងបានផ្ញើអ៊ីមែលទៅភាគីទាំងអស់ដោយលើកឡើងថា អង្គបុរេមិនទាន់បានបញ្ជូនសំណុំរឿងទៅអង្គជំនុំជម្រះសាលាដំបូងនៅឡើយទេ[9]។

8. នៅថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០២០[10] សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់ *សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំឱ្យចាត់រាល់វិធានការរដ្ឋបាលដែលចាំបាច់ទាំងអស់ដើម្បីបញ្ជូនសំណុំរឿង ០០៤/២ (អោ អាន) ទៅអង្គជំនុំជម្រះសាលាដំបូង* (*"សំណើសុំចាត់វិធានការរបស់ សហព្រះរាជអាជ្ញាអន្តរជាតិ"*)[11]។ មេធាវីការពារក្តីបានដាក់ចម្លើយតបទៅនឹង *សំណើសុំចាត់វិធានការរបស់សហព្រះរាជអាជ្ញាអន្តរជាតិ* នៅថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២០[12]។

9. នៅថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២០ ក្រឡាបញ្ជីនៃអង្គជំនុំជម្រះសាលាដំបូងបានផ្ញើអ៊ីមែលបន្តទៅភាគីទាំងអស់ដោយអះអាងសាជាថ្មីថា អង្គបុរេមិនទាន់បានបញ្ជូនសំណុំរឿងទៅអង្គជំនុំជម្រះសាលាដំបូងនៅឡើយទេ[13]។

## ច្បាប់ជាធរមាន

10. វិធាន ៦៩(២)(ខ) ចែងថា "នៅពេលដែលគ្មានបណ្តឹងឧទ្ធរណ៍ សហចៅក្រមស៊ើបអង្កេតត្រូវបិទសំណុំរឿងដោយមានបោះត្រាលើសំណុំរឿង និង [...] ប្រសិនបើមានដីកាលើកលែងការចោទប្រកាន់ សំណុំរឿងត្រូវបានរក្សាទុកក្នុងបណ្ណសារ ក្រោយពីផុតរយៈពេលធ្វើបណ្តឹងឧទ្ធរណ៍"។ ពុំមានបទប្បញ្ញត្តិដូចគ្នា ចំពោះស្ថានភាពដែលដីកាសម្រេចលើកលែងចោទប្រកាន់ត្រូវបានបញ្ជាក់ ឬ

---

[9] អ៊ីមែលពីក្រឡាបញ្ជីនៃអង្គជំនុំជម្រះសាលាដំបូងផ្ញើជូនភាគីពាក់ព័ន្ធនឹងសំណុំរឿង ០០៤/០២ ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០២០ ត្រូវបានភ្ជាប់ជាឧបសម្ព័ន្ធ ២។

[10] ឯកសារនេះបានជូនដំណឹងដល់មេធាវីការពារក្តីនៅថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២០។

[11] សំណុំរឿងលេខ ០០៤/២/០៧-០៩-២០០៩-អវតក/អជសដ *សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំឱ្យចាត់រាល់វិធានការរដ្ឋបាលដែលចាំបាច់ទាំងអស់ដើម្បីបញ្ជូនសំណុំរឿង ០០៤/២ (អោ អាន) ទៅអង្គជំនុំជម្រះសាលាដំបូង* (*"សំណើសុំចាត់វិធានការរបស់ ស.ព.អ"*) ឯកសារ **D359/25 & D360/34** ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០២០។

[12] សំណុំរឿងលេខ ០០៤/២/០៧-០៩-២០០៩-អវតក/អជសដ *ចម្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំឱ្យចាត់វិធានការដែលចាំបាច់ទាំងអស់ដើម្បីបញ្ជូនសំណុំរឿង ០០៤/២ (អោ អាន) ទៅអង្គជំនុំជម្រះសាលាដំបូង* ឯកសារ **D359/26 & D360/35** ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២០។

[13] អ៊ីមែលពីក្រឡាបញ្ជីនៃអង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធនឹងសំណើរបស់ ស.ព.អ ថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០២០ ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២០ ត្រូវបានភ្ជាប់ជាឧបសម្ព័ន្ធ ៣។

មិនត្រូវបានបដិសេធដោយសារបណ្តឹងឧទ្ធរណ៍នោះទេ (គឺថា សេចក្តីសម្រេចរបស់ អង្គបុរេ ឬ ដោយសារលទ្ធផលនៃការខកខានរបស់អង្គបុរេជំនុំជម្រះ ដែលមិនអាចរកបានសំឡេងគាំទ្រភាគច្រើនលើសលប់)។ ហេតុនេះ វិធាន ៦៩(២)(ខ) ត្រូវអនុវត្ត*ដូចគ្នា*ចំពោះស្ថានភាពនេះ។

11. វិធាន ៧៧(១៣)(ក) ចែងថា ប្រសិនបើសំឡេងភាគច្រើនដែលតម្រូវមិនអាចរកបាន *ពាក់ព័ន្ធនឹងបណ្តឹងឧទ្ធរណ៍ដែលមិនមែនជាដីកាបញ្ជូនរឿងទៅជំនុំជម្រះទេ* សេចក្តីសម្រេចដែលមិនមានសំឡេងគាំទ្ររបស់អង្គបុរេជំនុំជម្រះត្រូវតម្កល់ទុកជាបានការ។

12. មាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាចែងថា វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ។ គោលការណ៍ដដែលនេះត្រូវបានទទួលយកជាសាកលដោយមានចែងនៅក្នុងមាត្រា ១៤(២) នៃកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។

13. សិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ មានចែងនៅក្នុងមាត្រា ១៣ នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលកម្ពុជាប្រជាធិបតេយ្យធ្វើនៅរាជធានីភ្នំពេញ ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០០៣ (*"កិច្ចព្រមព្រៀងរវាង អ.ស.ប និង រាជរដ្ឋាភិបាលកម្ពុជា"*) មាត្រា ៣៣ ដល់ ៣៥*ថ្មី* នៃច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ដែលត្រូវបានធ្វើវិសោធនកម្មនៅថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤ (*"ច្បាប់ អ.វ.ត.ក"*) និង វិធាន ២១[14]។

## សំណើសុំការបញ្ជាក់

14. មេធាវីការពារក្តីស្នើសុំដល់ អង្គបុរេជំនុំជម្រះមេត្តាបញ្ជាក់ថាខ្លួនបានចាត់វិធានការរដ្ឋបាលដែលចាំបាច់ទាំងអស់ដើម្បីរក្សាសំណុំរឿង ០០៤/០២ ទុកក្នុងបណ្ណសារ អនុលោមតាមវិធាន ៦៩(២)(ខ)។

15. *ដីកាសម្រេចលើកលែងចោទប្រកាន់* អនុលោមតាមវិធាន ៦៧(២) ត្រូវបានចេញនៅថ្ងៃទី១៦ ខែ

[14] កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលកម្ពុជាប្រជាធិបតេយ្យ រាជធានីភ្នំពេញ ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០០៣ (*"កិច្ចព្រមព្រៀងរវាង អ.ស.ប និង រ.រ.ក"*) មាត្រា ១៣។ នៃច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ដែលត្រូវបានធ្វើវិសោធនកម្មនៅថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤ (នស/រកម/១០០៤/២០០៦) (*"ច្បាប់ អ.វ.ត.ក"*) មាត្រា ៣៣, ៣៥ *ថ្មី*។ វិធាន ២១។

សីហា ឆ្នាំ២០១៩ ក្នុងសំណុំរឿង ០០៤/០២។ សហព្រះរាជអាជ្ញាអន្តរជាតិបានប្ដឹងឧទ្ធរណ៍ប្រឆាំងនឹង *ដីកាសម្រេចលើកលែងចោទប្រកាន់* ក៏ប៉ុន្តែ អង្គបុរេជំនុំជម្រះមិនអាចរកបានសំឡេងគាំទ្រភាគច្រើនលើសលប់ដើម្បីសម្រេចទៅលើអង្គសេចក្ដីនៃបណ្ដឹងឧទ្ធរណ៍នោះទេ[15]។ អនុលោមតាមវិធាន ៧៧(១៣)(ក) ប្រសិនបើសំឡេងភាគច្រើនដែលតម្រូវមិនអាចរកបានពាក់ព័ន្ធនឹងបណ្ដឹងឧទ្ធរណ៍ដែលមិនមែនជាដីកាបញ្ជូនរឿងទៅជំនុំជម្រះទេ សេចក្ដីសម្រេចដែលមិនមានសំឡេងគាំទ្ររបស់អង្គបុរេជំនុំជម្រះត្រូវតម្កល់ទុកជាបានការ។ ហេតុនេះ *ដីកាសម្រេចលើកលែងចោទប្រកាន់* មិនត្រូវបានប៉ះពាល់ដោយបណ្ដឹងឧទ្ធរណ៍ទេ។ ការណ៍ដែលថា *ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ)* ក៏អាចតម្កល់ទុកជាបានការដែរ អនុលោមតាម វិធាន ៧៧(១៣)(ខ) មិនមានអានុភាពទៅលើសុពលភាពរបស់ *ដីកាសម្រេចលើកលែងចោទប្រកាន់* ឡើយ។

16. ទោះបី អង្គបុរេជំនុំជម្រះបានសម្រេចជាឯកច្ឆ័ន្ទថា ការចេញដីកាដំណោះស្រាយពីរជារឿងខុសច្បាប់ក្ដី[16] តែអង្គជំនុំជម្រះមិនអាចរកបានសំឡេងគាំទ្រភាគច្រើនលើសលប់ ដើម្បីសម្រេចទៅលើអានុភាពនៃភាពខុសច្បាប់នេះ និងផលវិបាកផ្នែកនីតិវិធីសម្រាប់សំណុំរឿង ០០៤/០២ ទេ។[17]។ ចៅក្រមភាគច្រើននៅ អង្គបុរេ បានសម្រេចថា គោលការណ៍ *វិមតិសង្ស័យបានជាប្រយោជន៍ដល់ជនជាប់ចោទ* តម្រូវឲ្យច្រានចោលសំណុំរឿង ០០៤/០២[18]។ ចៅក្រមភាគតិចនៅ អង្គបុរេ មិនយល់ស្របទេ។ ទោះជាយ៉ាងណាក្ដី ចៅក្រមពីររូបនៅ អង្គបុរេ មិនអាចបដិសេធការយល់ឃើញរបស់មតិភាគច្រើន ឬបង្គាប់ជាឯកតោភាគីដល់ក្រឡាបញ្ជីរបស់អង្គបុរេ ក្នុងការបញ្ជូនសំណុំរឿងទៅអង្គជំនុំជម្រះសាលាដំបូងបានឡើយ[19]។

17. ក្របខណ្ឌគតិយុត្តិនៅ អ.វ.ត.ក មិនអាចដោះស្រាយភាពជាប់គាំង ដោយសារការចេញដីកាដំណោះស្រាយពីរដាច់ដោយឡែកពីគ្នា និងផ្ទុយគ្នា ដែលពុំមានដីកាណាមួយក្នុងចំណោមនោះត្រូវបានបដិសេធដោយសំឡេងគាំទ្រភាគច្រើនលើសលប់ នៅពេលសម្រេចទៅលើបណ្ដឹងឧទ្ធរណ៍នោះទេ[20]។ អនុលោមតាមគោលការណ៍ *វិមតិសង្ស័យបានជាប្រយោជន៍ដល់ជនជាប់ចោទ* ដែលមាន

[15] *សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍* កថាខណ្ឌ ១៦៩។

[16] *សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍* កថាខណ្ឌ ១២៣-១២៥។

[17] *សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍* កថាខណ្ឌ ១២៤, ១៧០-៣០២, ៣០៤-៣២៩។

[18] *សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍* កថាខណ្ឌ ២៩៥-៣០២។

[19] *សំណើសុំចាត់វិធានការរបស់ ស.ព.អ* កថាខណ្ឌ ២៥។

[20] *សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍* កថាខណ្ឌ ២៩៥-៣០២។

ចែងក្នុងមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញកម្ពុជា និងមាត្រា ១៤(២) នៃកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ រាល់ការជាប់គាំង និងភាពមិនច្បាស់លាស់ទាំងអស់ត្រូវដោះស្រាយជាប្រយោជន៍ដល់ អោ អាន។ ក្រៅពីនេះ សិទ្ធិរបស់ អោ អាន ក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ដោយសាលាក្តីមានសមត្ថកិច្ចដែលបង្កើតឡើងដោយច្បាប់បង្ហាញថាការយល់ឃើញរបស់ចៅក្រមភាគច្រើនមិនអាចមិនអើពើបានឡើយ[21]។ ចុងក្រោយ គេគួរកត់សម្គាល់ថា *ដីកាសម្រេចលើកលែងចោទប្រកាន់* ត្រូវបានចុះបញ្ជីក្នុងសំណុំរឿងមុន *ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ)*។ ហេតុនេះ *ដីកាសម្រេចលើកលែងចោទប្រកាន់* ដែលទទួលប្រយោជន៍ពីការគាំទ្រដោយចៅក្រមភាគច្រើន និង សហព្រះរាជអាជ្ញាជាតិនោះ ត្រូវមានអាទិភាពទៅលើ *ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ)*។ ហេតុនេះ សំណុំរឿងប្រឆាំង អោ អាន ត្រូវបានច្រានចោលយ៉ាងដាច់ស្តែង។

18. អនុលោមតាមវិធាន ៦៩(២)(ខ) “ប្រសិនបើមានដីកាលើកលែងការចោទប្រកាន់ សំណុំរឿងត្រូវបានរក្សាទុកក្នុងបណ្ណសារ”។ ទោះបី វិធាន ៦៩(២)(ខ) អនុវត្តដោយផ្ទាល់ចំពោះស្ថានភាពដែលគ្មានការប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើកលែងចោទប្រកាន់ក៏ដោយ ក៏ពុំមានបទប្បញ្ញត្តិដូចគ្នាចំពោះស្ថានភាពដែលដីកាសម្រេចលើកលែងចោទប្រកាន់ត្រូវបានបញ្ជាក់ ឬមិនត្រូវបានបដិសេធដោយសារបណ្តឹងឧទ្ធរណ៍នោះទេ (គឺថា ដោយសំឡេងគាំទ្រភាគច្រើនលើសលប់ពីចៅក្រមនៅ អង្គបុរេជំនុំជម្រះ ឬជាលទ្ធផលដែល អង្គបុរេ មិនអាចរកបានសំឡេងគាំទ្រភាគច្រើនលើសលប់)។ ភាពសមហេតុសមផលបង្ហាញថា នៅក្នុងកាលៈទេសៈទាំងនេះ សំណុំរឿងត្រូវ

---

[21] សិទ្ធិនេះមិនត្រឹមតែទម្រង់ប៉ុណ្ណោះទេ ហើយតម្រូវឲ្យស្របទៅនឹងបទដ្ឋាននីតិវិធីត្រឹមត្រូវជាមូលដ្ឋាន៖ គណៈកម្មាធិការសិទ្ធិមនុស្ស យោបល់ទូទៅលេខ ៣២ មាត្រា ១៤៖ សិទ្ធិទទួលបានសមភាពនៅចំពោះមុខតុលាការ និងសាលាក្តី និងសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ ឯកសារ អ.ស.ប លេខ CCPR/C/GC/32 (ឆ្នាំ២០០៧) កថាខណ្ឌ ១៨ ត្រូវបានភ្ជាប់ជាឧបសម្ព័ន្ធ ៤។ *រឿងក្តី រដ្ឋអាជ្ញា ទល់នឹង* Karadžić សំណុំរឿងលេខ IT-95-5/18-T *សេចក្តីសម្រេចលើសំណើរបស់ជនជាប់ចោទជំទាស់ទៅនឹងសុពលភាពគតិយុត្តិ និងភាពស្របច្បាប់របស់សាលាក្តី* ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០០៩ កថាខណ្ឌ ១៣ ត្រូវបានភ្ជាប់ជាឧបសម្ព័ន្ធ ៥ កថាខណ្ឌ ១៣ (“[…] តុលាការព្រហ្មទណ្ឌអន្តរជាតិត្រូវ “បានបង្កើតឡើងដោយច្បាប់” នៅពេលដែលមាន “ប្រភពពីវិធាននៃច្បាប់ និងផ្តល់ការធានាទាំងអស់ដែលមានកំណត់នៅក្នុងលិខិតុបករណ៍អន្តរជាតិដែលពាក់ព័ន្ធ””) (ដកស្រង់ *រឿងក្តី រដ្ឋអាជ្ញា ទល់នឹង* Tadić សំណុំរឿងលេខ IT-94-1-AR72 *សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តីសុំប្តឹងឧទ្ធរណ៍បន្ទាន់បង្ខំទៅលើយុត្តាធិការ* ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ១៩៩៥ កថាខណ្ឌ ១០-១២)។ *រឿងក្តី* Richert *ទល់នឹង ប្រទេសប៉ូឡូញ* តុលាការ ECtHR ពាក្យសុំលេខ 54809/07 *សាលដីកា* ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០១២ កថាខណ្ឌ ៤៣ ត្រូវបានភ្ជាប់ជាឧបសម្ព័ន្ធ ៦ (“សាលាក្តីមួយដែលត្រូវបានបង្កើតឡើងដោយច្បាប់ ត្រូវបំពេញទៅលើលក្ខខណ្ឌមួយចំនួនដូចជា ឯករាជ្យភាពពីសមាជិក និងចិរវេលានៃមុខតំណែងរបស់សមាជិក ភាពមិនលម្អៀង និងអត្ថិភាពនៃការការពារផ្នែកនីតិវិធី”)។

តែយកទៅបោះត្រា និងរក្សាទុកក្នុងបណ្ណសារ អនុលោមតាមវិធាន ៦៩(២)(ខ)។

19. មកទល់នឹងពេលនេះ អោ អាន មិនទាន់បានទទួលការបញ្ជាក់ណាមួយថា សំណុំរឿង ០០៤/០២ ត្រូវបានបោះត្រា និងរក្សាទុកក្នុងបណ្ណសារទៅតាមការតម្រូវរបស់វិធានផ្ទៃក្នុងនៅឡើយទេ។ លទ្ធផលនៃភាពមិនច្បាស់លាស់ជាការរំលោភបំពានលើសិទ្ធិរបស់ អោ អាន ក្នុងការទទួលបានការសម្រេចជាស្ថាពរនៅក្នុងរឿងក្តីនេះ គោលការណ៍សច្ចភាពផ្លូវច្បាប់ និង បន្តប៉ះពាល់ដល់សុខមាលភាពរបស់គាត់។

20. អនុលោមតាមករណីយុត្តិសាស្ត្រដែលសមហេតុផលនៅតុលាការសិទ្ធិមនុស្សអឺរ៉ុប (*'ECtHR'*) ការធានានូវសិទ្ធិជាសារវ័ន្តក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ (ដែលមានចែងនៅក្នុងមាត្រា ១៣ នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និង រាជរដ្ឋាភិបាលកម្ពុជា និង មាត្រា ៣៣ ដល់៣៥ថ្មី នៃច្បាប់ អ.វ.ត.ក) *"រួមមានសិទ្ធិទទួលបានការសម្រេចស្ថាពរទៅលើបញ្ហាដែលបានដាក់ជូនតុលាការ"*[22]។ តុលាការ ECtHR បានសន្និដ្ឋានបន្ថែមថា *"ការរៀបចំដោយបោះឆ្នោតតែត្រូវបានរិតត្បិត [...] មិនផ្តល់ផលប្រយោជន៍នៃសច្ចភាពផ្លូវច្បាប់ និងអាចដកចេញ[ពីចុងចោទ] នូវសិទ្ធិទទួលបានការសម្រេចជាចុងក្រោយទៅលើ[សំណុំរឿង] របស់ខ្លួនយ៉ាងមានប្រសិទ្ធភាព[ដែលនាំឱ្យមានការរិតត្បិតទៅលើ] ខ្លឹមសារនៃសិទ្ធិរបស់គាត់ដែលទទួលបានការសម្រេចពីតុលាការ"* ហេតុនេះ វាជាការបំពានទៅលើសិទ្ធិរបស់គាត់ក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌[23]។

21. ជាងនេះទៀត ការពុំមានភាពច្បាស់លាស់ទាក់ទិននឹងលទ្ធផលស្ថាពរនៃសំណុំរឿង ០០៤/០២ នោះគឺជាបំបិទសិទ្ធិរបស់ អោ អាន ក្នុងការទទួលបានការវិនិច្ឆ័យលើសំណុំរឿងដោយសាលាក្តីមានសមត្ថកិច្ចដែលបង្កើតឡើងដោយច្បាប់។ ការពិតដែលមិនអាចប្រកែកបានគឺថា លទ្ធភាពនៃភាពមិនច្បាស់លាស់ ទោះបីគាត់នៅតែត្រូវប្រឈម ឬមិនត្រូវប្រឈមនឹងបទចោទនានាពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មទ្រង់ទ្រាយធំ រួមមានអំពើប្រល័យពូជសាសន៍ក៏ដោយ ក៏នៅតែប៉ះពាល់ដល់សុខុមាលភាពរបស់ អោ អាន ដែរ។ ចុងចោទមិនគួរក្លាយជាចំណាប់ខ្មាំងដោយសារការមិនដំណើរការទៅមុខរបស់សាលាក្តីនោះឡើយ ទោះបីការទទួលខុសត្រូវចំពោះការមិនដំណើរការទៅមុខនោះ

---

[22] *រឿងក្តី Marini ទល់នឹង ប្រទេសអាល់បានី* តុលាការ ECtHR *សាលក្រម* ពាក្យសុំលេខ 3738/02 ចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ ២០០៨ កថាខណ្ឌ ១២០ ត្រូវបានភ្ជាប់ជាឧបសម្ព័ន្ធ ៧។

[23] *រឿងក្តី Marini* កថាខណ្ឌ ១២២-១២៣។

ស្ថិតក្នុងសមត្ថកិច្ចរបស់ស្ថាប័នណាក៏ដោយ។

**សេចក្តីសន្និដ្ឋាន និង សំណើ**

22. ហេតុនេះ មេធាវីការពារក្តីស្នើសុំដោយគោរពដល់អង្គបុរេជំនុំជម្រះមេត្តាបញ្ជាក់ថាបានចាត់វិធានការដែលចាំបាច់ទាំងអស់ដើម្បីរក្សាសំណុំរឿង ០០៤/០២ ទុកក្នុងបណ្ណសារ។

សូមលោកចៅក្រមមេត្តាទទួលយកសំណើនេះដោយក្តីគោរព។

នៅរាជធានីភ្នំពេញ នៃព្រះរាជាណាចក្រកម្ពុជា ចុះហត្ថលេខានៅថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២០

**សហមេធាវីការពារក្តី អោ អាន**

មុំ លុជ្ស Richard ROGERS Göran SLUITER